# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ១៥៤ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការបង់វិភាគទានសេវារដ្ឋបាលសម្រាប់ដំណើរការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ-បក ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## សម្រេច

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការបង់វិភាគទានសេវារដ្ឋបាល របស់គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន ដើម្បីប្រើប្រាស់សម្រាប់ដំណើរការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) ក្នុងទិសដៅធានា និងពង្រឹងគុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា ។

**មាត្រា២.-**

គ្រឹះស្ថានឧត្តមសិក្សាត្រូវបង់វិភាគទានសេវារដ្ឋបាល នៅពេលស្នើសុំឱ្យ គ.ទ.ក ចុះវាយតម្លៃ ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ ។

ការបង់វិភាគទានសេវារដ្ឋបាល សម្រាប់ដំណើរការវាយតម្លៃដើម្បីទទួលស្គាល់គុណភាពអប់រំថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងដំណើរការវាយតម្លៃ ដើម្បីទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាទាំងមូលជាបន្ទុករបស់គ្រឹះស្ថានឧត្តមសិក្សា ពុំមែនជាបន្ទុករបស់និស្សិតទេ ។

វិភាគទានសេវារដ្ឋបាលដែលត្រូវបង់ ត្រូវគិតតាមចំនួននិស្សិតដែលកំពុងសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សានៃឆ្នាំសិក្សាដែលគ្រឹះស្ថានឧត្តមសិក្សាស្នើសុំឱ្យ គ.ទ.ក ចុះវាយតម្លៃ ។

**មាត្រា៣.-**

គ្រឹះស្ថានឧត្តមសិក្សាត្រូវបង់វិភាគទានសេវារដ្ឋបាល សម្រាប់ដំណើរការវាយតម្លៃដើម្បីទទួលស្គាល់គុណភាពអប់រំថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន តាមចំនួននិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានទាំងអស់ ដែលបានចុះឈ្មោះសិក្សាពេញម៉ោង និងមិនពេញម៉ោង ក្នុងទឹកប្រាក់ចំនួន ១០.០០០ រៀល (ដប់ពាន់រៀល) សម្រាប់និស្សិតមួយរូប ។

**មាត្រា៤.-**

គ្រឹះស្ថានឧត្តមសិក្សាត្រូវបង់វិភាគទានសេវារដ្ឋបាល សម្រាប់ដំណើរការវាយតម្លៃដើម្បីទទួលស្គាល់គុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាទាំងមូល តាមចំនួននិស្សិត ដែលបានចុះឈ្មោះសិក្សាពេញម៉ោង និងមិនពេញម៉ោងទាំងអស់ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ក្នុងទឹកប្រាក់ចំនួន ៥.០០០ រៀល (ប្រាំពាន់រៀល) សម្រាប់និស្សិតមួយរូប ។ ៤

**មាត្រា៥.-**

ការកែប្រែតម្លៃ និងការប្រើប្រាស់វិភាគទានសេវារដ្ឋបាល និងការណែនាំផ្សេងៗ ត្រូវកំណត់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងគ្រប់គ្រឹះស្ថានឧត្តមសិក្សា ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**__កន្លែងទទួល :__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ